# ការសំភាសន៍របស់ មឿង សំ

កៈ អ្នកដែរសំភាសន៍មាន រ៉េន សារិន        ខៈ អ្នកដែរអោយគេសំភាសន៍ មឿង សំ

កៈ
ជាដំបូងខ្ញុំសុំថ្លែងអំណរគុណដល់មីងដែរបានអោយខ្ញុំបានសំភាសន៍ពីប្រវត្តិរបស់មីងហើយការសំភាសន៍នេះត្រូវបានរៀបចំឡើងដោយសកលវិទ្យាល័យនៅអាមេរិចដែរមានឈ្មោះថាBYU
ហាសមីងដោយសារតែសកលវិទ្យាល័យមានគោលបំណងចង់រក្សាប្រវត្តិរបស់ប្រជាជនខ្មែរទាំងអស់ទុកអោយកូនចៅជំនាន់ក្រោយបានស្គាល់ពីប្រវត្តិដូនតា។

ខៈ យល់ព្រម។

កៈ
ចាចឹងពេលដែរខ្ញុំសំភាសន៍មីងនឹងខ្ញុំនឹងដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ហាសមីងចឹងខ្ញុំចង់សួរទៅមីងថាមីងតើមីងយល់ព្រមអោយខ្ញុំដាក់ការសំភាំសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាទេមីង?

ខៈ
យល់ព្រមតាមប្អូនដែរធ្វើបានប្អូនធ្វើកិច្ចការមួយនេះបានមីងយល់ព្រមណាស់នឹងហើយ។

កៈ ចឹងមីងសំរាប់ខ្ញុំជាអ្នកសំភាសន៍មីងខ្ញុំមានឈ្មោះថា រ៉េន សារិន
ហើយថ្ងៃខែដែរខ្ញុំសំភាសន៍មីងគឺនៅថ្ងៃទី11 ខែមេសា ឆ្នាំ2017
ហើយការសំភាសន៍នេះត្រូវបានធ្វើឡើងនៅភូមិព្រៃកស្វាយ ឃុំរាំងកេសី ស្រុកសង្កែ
ខេត្តបាត់ដំបងហាសមីងចាចឹងសុំសួរមីងបន្តិចថាតើមីងឈ្មោះអីគេដែរមីង?

ខៈ ខ្ញុំមានឈ្មោះថាសំ។

កៈ ចឹងមីងឈ្មោះសំ ចុះត្រកូលអីគេមីង?

ខៈ ត្រកូលមឿង សំ។

កៈ ឈ្មោះមឿង សំ ចុះមីងមានឈ្មោះហៅក្រៅទេ ?

ខៈ ឈ្មោះសំនេះហើយហៅក្រៅនោះ។

កៈ ចុះចឹងអត់មានឈ្មោះអីហៅផ្សេងទៀតទេណាមីង?

ខៈ អត់ទេគេហៅយាយជី។។

កៈ ចឹងគេហៅយាយជីណា?

ខៈ នឹងហើយ។

កៈ ចុះមីងមានអាយុប៉ុន្មានឆ្នាំហើយឆ្នាំនេះ?

ខៈ ខ្ញុំអាយុ50ឆ្នាំគត់។

កៈ ចឹងមីងមានអាយុ50ឆ្នាំគត់ចាហើយឆ្នាំខ្មែរតើមីងដឹងថាមីងកើតឆ្នាំអីទេ?

ខៈ ភ្លេចបាត់ហើយ ។

ក. ភ្លេចបាត់ហើយតើឆ្នាំបារាំងអីមីងមានចាំថ្ងៃទីប៉ុន្មានដែរទេមីង?

ខៈ អត់ចាំភ្លេចនៅលិចណោះគេទុកចោលនៅលិចអីណោះខ្ញុំមិនសូវត្រូវជាមួយតាទេ
នឹងហើយប៉ុណ្ណឹងបានហើយ។

កៈ ចាចឹងអត់ដឹងថ្ងៃខែឆ្នាំកំណើតរបស់មីងទេណា?

ខៈ វាភ្លេចបាត់ទៅហើយ។

កៈ ចឹងមីងដឹងតែមីងអាយុ50ឆ្នាំគត់?

ខៈ មីងដឹងតែ50ឆ្នាំទេ។

កៈ ចុះមីងមានដឹងថាតើមីងកើតនៅណាទេមីង?

ខៈ ខ្ញុំកើតនៅភូមិបាយដំរាម ។

កៈ ចុះឃុំអី ស្រុកអី ខេត្តអីចឹងហាស?

ខៈ ឃុំបាណន់ ស្រុកសង្កែ ខេត្តបាត់ដំបង។

ក៖ ចុះមីងតើមីងមានបងប្អូនប៉ុន្មាននាក់ដែរមីង?

ខ៖ ខ្ញុំមានបងប្អូន6នាក់ ប្រុស2នាក់ ស្រី4នាក់។។

ក៖ ចុះមីងជាកូនទីប៉ុន្មានដែរមីង?

ខ៖ ខ្ញុំជាកូនទី2

ក៖ ចាហើយមីងមានស្គាល់ឈ្មោះបងប្អូនរបស់មីងទេ?

ខ៖ ឈ្មោះសួត ឈ្មោះ សំ ឈ្មោះ ស៊ូ ឈ្មោះ ស៊ន ឈ្មោះ ស៊ាន ឈ្មោះម៉ាប់ ជាកូនពៅគេ។

ក៖ ចឹងមាន5នាក់ណាមីងណា?

ខ. មាន6នាក់។

ក៖
មាន6នាក់ចុះតើមីងអនុស្សាវរីយ៍អីគេជាមួយបងប្អូនមីងទេដូចជាមីងបានធ្វើអីគេខ្លះជាមួយពួកគាត់ហាសមីង?

ខ៖ ថាម៉េចស្តាប់អត់សូវបាន?

ក៖
តើមីងមានធ្លាប់មានអនុស្សាវរីយ៍មីងមានធ្លាប់បានធ្វើអីគេជាមួយពួកគាត់កាលពីនៅតូចៗដូចជាធ្លាប់រត់លេងជាមួយគ្នារឺលេងអីជាមួយគ្នាចឹងហោស?

ខ៖ ខ្ញុំអត់ចេះលេងអីទេចេះតែរក ចេះតែធ្វើការងារច្រូតកាត់ ក្នុងមួយឆ្នាំបាន៣0បាវ
ហើយបាន20បាវ ហើយអត់ យើងដើររកស៊ីល្ហេមល្ហាម ដើររកស៊ីក្រកំសត់
គ្មានអីទីពឹងទេកើតមកម៉ែស្លាប់ចោលនៅអាតយុ53 ឆ្នាំ
ហើយឪពុកនោះអាយុ47ឆ្នាំតែពួកគាត់បានស្លាប់ចោលអស់ហើយ
ហើយសព្វថ្ងៃនៅកំព្រាតែម្នាក់អែងនៅជាមួយប្តី ហើយប្តីគេធ្វើបាប់ទៀត។

ក៖
ចុះមីងតើមីងកាលបងប្អូនមីងកាលនៅតូចៗហាសតើមីងមានបានធ្វើអីគេខ្លះជាមួយពួកគាត់ហាស?

ខ៖ ជាមួយបងប្អូនហោស?

កៈ ចា!

ខៈ មានដក់ស្ទូង ច្រូតកាត់ ធ្វើនុំបញ្ចុកលក់ លក់ស្រា
ហើយលក់ត្រីឆ្អើរលក្ខណៈថាទូលលក់ហាស ការងារច្រើនមុខហាស មានមើលគោ។

កៈ ចូលចិត្តធ្វើការងារជាមួយពួកគាត់ណាមីងណា?

ខៈ នឹងហើយមានមើលគោ ច្រូតស្មៅគោ ដាំសណ្តែក ច្រូតស្មៅគោ
ហើយបន្ទាប់មកទៀតធ្វើស្រែនឹងធ្វើចំការនឹងហើយ។

កៈ ចុះមីងបងប្អូនរបស់មីងសព្វថ្ងៃតើពួកគាត់រស់នៅណាខ្លះដែរមីង?

ខៈ គេនៅព្រៃទទឹងនេះ4នាក់ស្រី នៅប្រុសនោះភូមិដូងនោះមួយ
នៅប្រុសនោះនៅលង្វាំនោះមួយនៅតែប៉ុណ្ណឹងអែង។

កៈ ហើយចុះគាត់ធ្វើការងារអីគេដែរមីង?

ខៈ គេធ្វើស្រែចំការ។

កៈ ចឹងពួកគាត់ក៏ធ្វើស្រែចំការដែរណាមីងណា?

ខៈ នឹងហើយ។

កៈ ចុះម្តាយរបស់មីងតើគាត់មានឈ្មោះអីគេដែរមីង?

ខៈ ម្តាយរបស់ខ្ញុំឈ្មោះ ស៊ាម ។

កៈ មីងមានត្រកូលរបស់គាត់ឈ្មោះអីទេមីង?

ខៈ ត្រកូលរបស់គាត់មានឈ្មោះអ៊ុំ ឈ្មោះ អ៊ុំស៊ាម ។

កៈ ចឹងគាត់មានឈ្មោះថាអ៊ុំ ស៊ាម  ចុះឪពុករបស់មីងនោះគាត់មានឈ្មោះអីគេដែរ?

ខៈ គាត់មានឈ្មោះថា មឿង សួន។

កៈ ចឹងគាត់មានឈ្មោះថា មឿង សួន
ចាចឹងតើពួកគាត់មានអាយុប៉ុន្មានដែរមីងបើគិតមកដល់សព្វថ្ងៃនេះហាសណា?

ខៈ បើនៅអាឡូវពុកប្រហែលជា78-79ឆ្នាំហើយ តែបើម៉ែប្រហែលជា75ឆ្នាំហើយ ។

កៈ ចាតើមីងមានចាំថាតើពួកគាត់កើតនៅឆ្នាំណាទេមីង?

ខៈ អត់ដឹងភ្លេចអស់ហើយ។។

ក. តែគាត់កើតនៅណាមីងមានចាំទេ?

ខៈ ម៉ែគាត់បានកើតនៅបាយដំរាម ពុកគាត់នៅលង្វាលហាស

កៈ ចុះមីងមានដឹងថាតើឪពុករបស់មីងគាត់ធ្វើអីគេសំរាប់ចិញ្ចឹមជីវិតហាសមីង?

ខៈ គាត់ធ្វើស្រែចំការ។

កៈ គាត់ធ្វើតែស្រែចំការទេ?

ខៈ នឹងមើលគោ។

កៈ តើគាត់ជាមនុស្សយ៉ាងម៉េចដែរមីងគាត់កាចរឺមួយក៏ស្លូត
គាត់មានលក្ខណៈយ៉ាងម៉េចដែរមីងបានស្គាល់ហាស?

ខៈ ឪពុករបស់ខ្ញុំស្លូតណាស់មិនដែរវៃកូនទេ តែបើម៉ែធ្លាប់បានវៃកូនខ្លះម៉ែគាត់កាច
សំរាប់ម៉ែគាត់កាចនឹងហើយ។

កៈ ចុះម្តាយរបស់មីងតើគាត់បានធ្វើអីគេខ្លះដែរសំរាប់ចិញ្ចឹមជីវិតហាសមីង?

ខៈ គាត់ធ្វើស្រែចំការ ឪពុកគាត់ក៏ធ្វើស្រែចំការម្តាយក៏គាត់ធ្វើស្រែចំការដូចតែគ្នានឹង។

កៈ ចុះម្តាយរបស់មីងគាត់មនុស្សយ៉ាងម៉េចដែរតើគាត់ជាមនុស្សកាច រឺមួយក៏ស្លូតដែរមីង?

ខៈ
ម៉ែគាត់កាចបន្តិចបើញ្ញាតិណាធ្វើចិត្តល្អជាមួយគាត់គាត់ក៏ធ្វើចិត្តល្អជាមួយនឹងគេវិញដែរកាចហាស ពូជកាច ពូជស៊ីមបណ្តោយពូជកាចហាស។

កៈ
ចាចុះមីងមានចងចាំសាច់រឿងអីជាមួយពួកគាត់ទេតើមីងធ្លាប់បានធ្វើអីគេខ្លះជាមួយម្តាយឪពុករបស់មីងហាសណា?

ខៈ ហោសម៉ែវៃអោយតែក្រោកពីដេកព្រលឹមឡើងវៃកេទឹកដាក់ក្នុងពាង ច្រូតស្មៅគោ
កាប់អូស ដឹកគោមកក្រោល ហើយដាំបាយហូបនឹងហើយ ហើយពុកហោសព្យូរស្រែ

ធ្វើចំការនោះពុកនោះគាត់បំរើឪពុកបំរើម្ដាយទាំងអស់នឹងហើយ
ហើយម្ដាយឪពុកស្រលាញ់ហាសគាត់ចូលចិត្តនរណាអ្នកការងារគាត់ស្រលាញ់អ្នកការងារហាសហើយកំសត់ណាស់ទូលទឹករែក រែកទឹកដាក់ពាងនៅម៉ោង4-5ព្រឹកអីចឹងទៅរែកទឹកដាក់ពាងហើយក៏យកមកគាត់ធ្លាប់ចង់ស្លាប់ម្ដងហើយដុះចេញគាត់រអិល ហើយក៏ទាស់នឹងអាល្ងូនឹងបឺសស្លាប់បាត់ហើយ
យូរទឹកម៉ោង4ព្រឹកនឹងស្រាំងៗម៉ែថាកុំទៅយូរកូនយូងទឹកហោសយូងទឹកច្រើនៗបឺសស្លាប់ម្ដងហើយ ហើយគោស្មានឹងយោងដាក់គោហើយគោមានបួនដប់ម្ភៃ
មើលគោបណ្ដើរអីបណ្ដើរនិយាយរួមមានសព្វគ្រប់។

កៈ មីងនិយាយនឹងមីងហោស?

ខៈ នឹងហើយមីងនឹង

កៈ
ចាមីងតើម្ដាយឪពុករបស់មីងគាត់មានធ្លាប់បានប្រាប់ពីជីវៈប្រវត្តិកាលពីពួកគាត់នៅក្មេងទេមីង និយាយរួមគាត់មានធ្លាប់បានប្រាប់រឿងអីកាលពួកគាត់នៅក្មេងប្រាប់មីងទេ?

ខៈ គាត់មិនបាននិយាយអីផងបើគាត់ធ្វើតែស្រែចំការគាត់និយាយតែរឿងស្រែចំការនឹង។

កៈ
ពេលយប់ឡើងគាត់មិនដែរបាននិទានពីប្រវត្តិរបស់គាត់ថាកាលពីក្មេងគាត់ធ្លាប់បានពិបាកអីគេខ្លះចឹងទេណាមីង?

ខៈ ម៉ែវេទនាជាងគេហាស ព្រោះម៉ែកំសត់ធ្វើតែស្រែនឹងធ្វើចំការ លីអូសលីឈើ
នឿយហាសម៉ែរបស់ខ្ញុំហោសមិនដូចម៉ែរបស់គេទេកំសត់ណាស់ចិញ្ចឹមជីវិតកូនវេទនាណាស់គ្មាននរណាគេដូចទេនិយាយរួមគ្មាននរណាកំសត់ដល់ម៉ែខ្ញុំទេ
កម្មណាស់ម៉ែខ្ញុំវេទនាជាងគេកំសត់ណាស់រែកស្មៅគោ
ដាំអានេះដាំអានោះទៅកំសត់ហាសណាស់ម៉ែខ្ញុំបើនិយាយទៅខ្ញុំមិនពិននិយាយដូចគាត់ទេហើយដល់ពេលគាត់បានពុកខ្ញុំគាត់ធ្វើស្រែធ្វើចំការ គាត់អ្នកព្យួរមុនឪពុករបស់ខ្ញុំហើយម៉ែអោយពុកខ្ញុំព្យួរតាមក្រោយ គោកាចៗគាត់ប្រើបាន គោស្លូតគាត់មិនហ៊ានប្រើទេ។

កៈ ម៉ែរបស់មីងមែន?

ខៈ នឹងហើយគាត់ខ្លាំងហាសណាស់ម៉ែរបស់ខ្ញុំហាស
គាត់ខ្លាំងហាសណាស់គោសុទ្ធតែអាពាលម៉ែខ្ញុំចាប់តែថ្មុះទេជាប់បាត់ខ្លាចម្ដាយរបស់ខ្ញុំហាសណាស់កំសត់ហាស។

កៈ ចឹងគោកាចម៉ែមីងកាចជាងគោទៀត។

ខៈ នឹងហើយគាត់កាចជាងគោ។

កៈ
ចុះមីងមីងមានចងចាំជីដូនជីតាខាងម្ដាយរបស់មីងតើគាត់មានឈ្មោះអីគេខ្លះដែរទេមីង?

ខៈ ម្ដាយខ្ញុំឈ្មោះតាចឹក ឪពុកខាងម្ដាយខ្ញុំឈ្មោះតាចឹក។

កៈ ចុះម្ដាយ?

ខៈ ខាងម្ដាយខ្ញុំឈ្មោះយាយ វ៉ាត ។

កៈ ចឹងគាត់ឈ្មោះយាយវ៉ាត តាចឹក។

ខៈ នឹងហើយឈ្មោះយាយវ៉ាត នឹងតាចឹក។

កៈ ចុះខាងឪពុកមីងមានចាំទេ?

ខៈ ខាងឪពុក ខាងឪពុកខ្ញុំនឹងឈ្មោះតា សួន ខាងម៉ែខ្ញុំនឹងឈ្មោះយាយ
វ៉ាន់នឹងខាងឪរបស់ខ្ញុំហាសខាងឪពុកខ្ញុំឈ្មោះយាយវ៉ាន់ ហើយឪពុកខ្ញុំឈ្មោះតាសួន។

កៈ ចុះមីងមានចាំថាពួកគាត់កើតនៅឆ្នាំណាទេមីង?

ខៈ អត់ដឹងភ្លេចអស់ហើយ។

កៈ ចុះពួកគាត់កើតនៅកន្លែងណាមីងដឹងទេ?

ខៈ ភ្លេចមិនដឹងកើតនៅកន្លែងណា?

កៈ ភ្លេចអស់អស់ហើយណាមីង
ចុះម្ដាយឪពុករបស់មីងគាត់មានប្រាប់មីងថាជីដូនជីតារបស់មីងពួកគាត់ជាមនុស្សយ៉ាងម៉េច ហើយពួកគាត់ធ្វើអីទេមីង?

ខ៖ ពួកគាត់ចូលចិត្តតែធ្វើស្រែចំការប៉ុណ្ណឹងអែង។

ក៖ ចឹងពួកគាត់អត់មានចូលចិត្តធ្វើអីទៀតទេណាមីង?

ខ៖ អត់ទេពួកគាត់ចូលចិត្តតែធ្វើស្រែចំការរហូត។

ក៖ ចាហើយចឹងពួកគាត់ធ្លាប់បានធ្វើអីខ្លះពួកគាត់មិនដែរប្រាប់ទេណាមីងណា?

ខ៖ អត់ទេពួកគាត់មិនដែរប្រាប់ទេ។

ក៖ ចាចុះមីងគ្រួសាររបស់មីងរបស់នៅខេត្តបាត់ដំបងនេះយូរនៅ?

ខ៖ គាត់ស្រុកកំណើតរបស់គាត់នៅបាត់ដំបងនេះតាំងពីសង្គមមកម្លេ៉ស
តាំងពីដូនតារបស់គាត់នៅតាំពីសង្គមមកហាស ដោយសារតែគាត់កំសត់ជាងគេ
ហើយគាត់កម្មជាងគេ។

ក៖ ចឹងគាត់នៅទីនេះប្រហែលប៉ុន្មានឆ្នាំហើយមីង
ហើយទាំងគាត់នឹងទាំងមីងនៅទីនេះបានប៉ុន្មានឆ្នាំហើយមីង?

ខ៖ នៅទីនេះនៅតាំងពីនៅតូចនៅងារមករហូតមកដល់សព្វថ្ងៃច័ន្ទ។

ក៖ ចឹងមីងនៅទីនេះប្រហែលជា50-60ឆ្នាំហើយនេះមីង?

ខ៖ នឹងហើយប្រហែលជា50-60ឆ្នាំហើយនឹងហើយនៅតាំងពីតូចមក។

ក៖ ចុះមីងមានសាច់ញ្ញាតិណាដែររស់នៅក្រៅប្រទេសទេមីង?

ខ៖ អត់មានផងមានតែគេមិនអោយមានជីដូនមួយតែគេមិនអោយយើងមួយរៀលទេ។

ក៖ ចុះគាត់នៅណាដែរមីង?

ខ៖ មីមួយទៅនៅអូស្រ្តាលីគេអោយ1000លុយខ្មែរ
ហើយមីងមួយគេអោយ10000លុយខ្មែរកាលពីនៅតូចហាសនឹងហើយគេអោយតែប៉ុណ្ណឹង
អែង។

ក៖ ចាចឹងគេនៅអូស្រ្តាលីណាមីងណាចុះមីងមានដែរតេសួរសុខទុករឺទាក់ទងទៅគេទេ?

ខ៖
អត់អត់ហ៊ានទាក់ទងទៅគេទេពីព្រោះតែគេអត់ចូលចិត្តយើងគេមិនត្រូវជាមួយយើងខ្ញុំមិនដែររករឿងគេទេតែគេមិនចូលចិត្តយើងនឹងហើយ។

ក៖ ចាចុះមីងស្វាមីរបស់មីងដូចជាប្តីរបស់មីងគាត់មានឈ្មោះអីគេដែរ?

ខ៖ អូប្តីរបស់មីងគាត់ក៏ឈ្មោះតាសួន ។

ក៖
អូគាត់ឈ្មោះតាសួនដែរណាចុះមីងមានចាំថាតើថ្ងៃណាដែរមីងបានរៀបអាពាហ៍ពិពាហ៍ជាមួយគាត់ដែរទេ មីងមានចាំថាពេលណាដែរមីងាបានរៀបការជាមួយគាត់ទេ?

ខ៖ ចាំពីខែថ្ងៃ11រោច ខែជេស។

ក៖ ចុះនៅឆ្នាំណាដែរមីង?

ខ៖ ថ្ងៃ11 ខែជេស ឆ្នាំអីទេនេះ4ឆ្នាំដែរហើយ?

ក៖ 4ឆ្នាំដែរហើយណាមីងចឹងមានតែឆ្នាំ2013?

ខ៖ នឹងហើយ។

ក៖
ចុះមីងពេលដែរមីងបានរៀបអាពាហ៍ពិពាហ៍នឹងតើមីងបានសំរេចចិត្តរៀបដោយខ្លួនអែងរឺមួយក៏មានការសំរេចចិត្តពីក្រុមគ្រួសាររបស់មីង?

ខ៖ កាលពីរៀបអាពាហ៍ពិពាហ៍នឹងគឺរៀបចំដោយចិត្តអែង។

ក៖ ចុះពេលរៀបអាពាហ៍ពិាពាហ៍នឹងដូចជាមានថ្លៃបណ្ណាការទេមីង?

ខ៖ កាលណុងគេដណ្តឹងត្រឹមត្រូវ គេបានចូលត្រឹមត្រូវហើយមានបងប្អូនគេដឹងលឺដែរតាតែម៉ែឪគ្មានទេមានតែមីងមាដែរមកហាសនឹងហើយ។

ក៖ ហើយមានបណ្ណាការប៉ុន្មានដែរមីង?

ខ៖ ចាសុំម្តតទៀត?

ក៖ ថ្លៃជំនួនហាសមីងប៉ុន្មានដែរមីង?

ខ៖ គេអោយជំនួន50ម៉ឺន។

ក៖ ចឹងបាន50ម៉ឺនណាមីង?

ខ៖ ហើយយើងយកមកកាន់ខ្លួន យើងមានថ្លៃលក់គោចំនួន4000បាទនឹងហើយ។

ក៖ ចុះមីងមីងមានចាំថាកាលពីមីងបានជួបលោកតា
ហើយមីងហេតុអីបានជាស្រលាញ់ជាមួយតាហាសអីចឹងហាស?

ខ៖ អត់ដែរមានចិត្តថាស្រលាញ់ផងលឺថាចង់បានក៏គេមានចិត្តយកទៅ
អត់មានចិត្តអីថាចង់បានរឺចេះស្រលាញ់អីគេទេ លឺថាគេចង់បានក៏យកគេទៅ
សំរាប់បំរើគ្នាទៅវិញទៅមក
ដល់ពេលគេបានយើងមកគេធ្វើបាប់យើងមិនដឹងធ្វើម៉េចនឹងហើយគេវៃធ្វើបាប់ចង់ងាប់
នឹងកូនគេអោយវៃគេវៃឡើងជាំខ្លួន គេធាក់
គេទាត់ម៉ាទំហឹងៗឡើងជិតងាប់ហើយយើងហាស
អានឹងកម្មវាសនារបស់យើងដែរយើងបានសាងពីជាតិមុនមក
ហើយគេថាយើងធ្វើបាប់កូនគេ
តើយើងចេះធ្វើអីយើងមិនចេះធ្វើអីកូនគេទេមិនចេះរករឿងគេទេ។

ក៖ ចុះមីងមីងចេះអាននឹងចេះសរសេរអក្សរខ្មែរបានល្អប៉ុណ្ណាដែរមីង?

ខ៖ អក្សរពីដើមមកចេះរៀនហើយចេះមើលតែដល់ពេលត្រូវរបស់គេពេញចឹងរយះពេល1-2ឆ្នាំចង់ភ្លេចអស់ហើយ

ក៖ ចឹងពីមុនមីងចេះសរសេរបានអានបានណាមីង?

ខ៖ តែសព្វថ្ងៃមិនបានទេរៀនទៅងុកងុយដោយសារតែត្រូវរបស់វានឹង
វាអោយងោកអោយងុយមិនអោយរៀនមិនអោយអីទេ រៀនបាលីរៀនធ៌ម
រៀនធ៌មឡើងចង់ចេះប្រែហើយក៏ឈប់ទៅវិញអត់មានទៅទេដោយសារតែត្រូវរបស់គេ។

ក៖ ចាចុះមីងមានចេះភាសាអីផ្សេងក្រៅពីភាសាខ្មែរទេមីង?

ខ៖ ចា?

ក៖ ចង់និយាយថាមីងមានចេះភាសាអីផ្សេងក្រៅពីភាសាខ្មែរទេមីងដូចជាភាសាជប៉ុន
ភាសាថៃអីមីងមានចេះទេ?

ខ៖ អត់អត់មានចេះទេអត់ចេះអីទេ។

ក៖ ចឹងមីងមិនចេះសោះម៉ងហោសមីង?

ខ៖ ខ្ញុំមិនចេះទេ។

ក៖ ចុះមីងមីងរៀនបានថ្នាក់ទីប៉ុន្មានដែរមីង?

ខ៖
ខ្ញុំរៀនបានថ្នាក់ទី2តែបើខំមកចេះអក្សរដែរបងប្អូនមិនសូវចេះប៉ុន្មានទេគេរៀនបានថ្នាក់ទី4នឹងទី3 ដែរតែគេមិនចេះមើលគេមើលមិនដាច់។

ក៖ ចាចឹងចាញ់មីងវិញ?

ខ៖ ចាចាញ់យើងហោសបើនិយាយរឿងអក្សរមើលទៅឆៅដែរហាស។

ក៖ ចុះពេលមីងរៀននៅថ្នាក់ទី2នឹងតើមីងរៀននៅណាដែរមីង?

ខ៖ រៀនថ្នាក់ទី2រៀនដែរយួនចូល។

ក៖ ចុះមីងមីងរៀននៅសាលាណាដែរមីង?

ខ៖ រៀននៅសាលាអិនចិត។

ក៖ នៅសាលាអិនចិតណាមីង?

ខ៖ នឹងហើយ។

ក៖ ចុះមានសាលាអីផ្សេងទៀតដែរមីងបានរៀនទេ?

ខ៖ សព្វថ្ងៃគេមានលង្វា គេមានលង្វា5-6ខ្នង។

ក៖ ចាតែមីងមានធ្លាប់បានរៀននៅសាលាអីផ្សេងទៀតអត់?

ខ៖
អត់បានរៀនទេរៀនបានតែនៅលើផ្ទះអង្គុយលើផ្ទះបានរៀនជាមួយគ្រូរយស្គាល់ដែរតាហីគ្រូរយ?

ក៖ ខ្ញុំអត់ស្គាល់ផង។

ខ៖ គ្រួរយនឹងត្រូវជាមីងរបស់ខ្ញុំ។

ក៖
ចុះមីងតើមីងធ្លាប់មានមិត្តភក្តិណាស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាទេដែរជាមិត្តភក្តិសំលាញ់ហាសមីង?

ខ៖ អត់ដែរមានទេ
អត់មានសង្សារីស្គាល់មិត្តភក្តិអីទេឃើញគ្នាចេះតែហៅទៅមិនចេះមានសង្សារីមានមិត្តភក្តិអីទេបើសិនគេសុំធ្វើម៉ែធ៍មមិនអោយធ្វើទេ
ព្រោះតែខ្លាចគេហាសញ្ញាតិចេះតែស្រលាញ់ហើយមិនចេះស្អប់ខ្ពើមនរណាគេទេនឹងហើយ។

ក៖ ចុះមីងតើមីងធ្លាប់បានធ្វើការនៅវាលស្រែទេ?

ខ៖ ខ្ញុំធ្លាប់តា។

ក៖ ចុះមីងធ្លាប់បានធ្វើអីគេខ្លះដែរនៅវាលស្រែដែរ?

ខ៖ មើលគោ កាប់អូស ទូលអូសមកផ្ទះ ចងគោចោលអោយទឹកគោ ដាំបាយហូប។

ក៖ ចុះស្វូងដក់អីហោសតើមីងធ្លាប់ធ្វើពីមុនអត់មីង?

ខ៖ ចេះមុកម្រឹក ចេះបុកម្ទូរ

ក៖ ប៉ុន្តែស្ទូងដក់មីងធ្លាប់អីទេ?

ខ៖ ស្ទូងដក់ធ្លាប់មើលអោយតែម៉ោង4ព្រឹលឡើងៗចាប់ដក់សំណាបហើយភ្លឺឡើងទៅស្ទូងជូនកាលក្រោកម៉ោង2អីចឹងទៅទៅដក់សំណាប់ហើយភ្លឺឡើងម៉ែក៏បបរអោយហូប។

ក៖ ចុះមីងធ្លាប់បានធ្វើមុខរបរអាជីវកម្មដូចជាលក់ដូរ ចិញ្ចឹមជ្រូក ចិញ្ចឹមទាអីទេមីង?

ខ៖ ចិញ្ចឹមដែរកាលពីយួនចូលមកនឹងចិញ្ចឹមដែរចិញ្ចឹមជ្រូក2-3ក្បាលដែរ
ហើយធ្វើស្រាម៉ែធ្វើស្រាទៅយើងជាអ្នកដើរលក់ ហើយចិញ្ចឹមជ្រូកទៅចិញ្ចឹមជ្រូក2-3ក្បាលមានកូនៗ នឹងមេជ្រូកនឹង2-3ក្បាលដែរចឹងទៅមើល។

ក៖ ចុះមីងនៅក្នុងជីវិតរបស់មីងហាសតើមីងធ្លាប់បានធ្វើអីគេខ្លះដែរមីង?

ខ៖ ខ្ញុំសព្វថ្ងៃនឹងហោស?

ក៖ ចាតាំងពីតូចរហូតមកដល់អាឡូវហាសតើមីងធ្លាប់បានធ្វើអីគេខ្លះដែរមីង?

ខ៖ ដក់សំណាប កាប់អូស មើលគោ ហើយច្រូតស្រូវហើយស្រូវនឹងច្រូត1ឆ្នាំបាន30បាវឈ ហើយបាន25បាវពេលអត់ពីម្ដាយទៅហោសមួយថ្ងៃបើមួយកុងបានមួយកុងកន្លះក្នុងមួយថ្ងៃហោសព្រលប់ឡើងចេញ ហើយទៅលែម9ឆ្នាំហើយទៅរកស៊ីនឹងហោស ក្នុង1ឆ្នាំបាន5000បាតទៅ6000បាតរឺក៏10000បាតពេលមកវិញហោក៏អស់លុយទៅដោយសារតែឈឺចាក់ថ្នាំមើលខ្លួនៗហើយ។

ក៖ ចុះមីងធ្លាបបានធ្វើអីគេខ្លះនៅលែមនឹងមីង?

ខ៖ ច្រូតស្មៅអោយគេ ជំរះស្មៅអោយគេ ដាំដំឡូងហើយកាចពោត ក្នុងមួយថ្ងៃបាន5បាវទៅខ្លះទៅបាន4បាវទៅខ្លះទៅក៏បាន6-7បាវទៅអានឹងកាចពោតហាសបើខ្លាចខ្ញុំកុហាកសួរមីងមាខ្ញុំនៅលែមនឹងទៅ តែបើនិយាយពីបេះសណ្ដែកវិញមួយថ្ងៃបាន30គីឡូ ទៅ50គីឡូលើសគេពីទៅបីគីឡូចឹងហាស។

ក៖ ចឹងមីងធ្លាប់បានធ្វើការងារច្រើនដែរណាមីង?

ខ៖ ហោសកាលណុងនឿយហាសយើងត្រូវខំបើមិនខំ។

ក៖
ចុះមីងពេលដែរមីងនៅកាលពីក្មេងហាសរហូតមកដល់អាឡូវតើមីងគិតថាជីវិតរបស់មីងមានការផ្លាស់ប្ដូរអីគេខ្លះដែរមីង?

ខ៖ ផ្លាស់ប្ដូរថាពេលមានប្ដីកាប់ថ្នាំលក់ លក់ថ្នាំស្បូន ដុះគីសស្បូន ដំគីស្បូន ដុះសរសៃគីសស្បូន មហារីកស្បូន មានថ្នាំក្រពះ ថ្នាំពោះវៀន សំរកខ្លាញ់រំបេះដូង រំពោះវៀន រំក្រពេះ ឈឺសន្លាក់ដៃ សន្លាក់ជើង ពុះឆ្អឹង មហាឆ្អឹង ស្ពួនឆ្អឹង ហើយថ្នាំថ្លើម នឹងទាយទឹកនរណាគេកើតទាយទឹកចឹងហាស។

ក៖ ចឹងមីងធ្វើដូចជាប្រកបមុខរបរថ្មីណាមីងណា ហើយមីងតើមីងចូលចិត្តពិសារម្ហូបអីគេដែរមីង?

ខ៖ ខ្ញុំចូលចិត្តម្ហូបស្លម្ជូរ។

កៈ មីងចូលចិត្តសំលម្លូរណាចឹងអោយតែម្ហូរចូលចិត្តទាំងអស់មែនមីង?

ខៈ នឹងហើយចូលចិត្តស្ងោរ ។

កៈ ចឹងមីងចូលចិត្តសម្លស្ងោរនឹងសំលម្ហូរ
ចុះមីងចូលចិត្តលេងល្បែងប្រជាប្រិយ៍ខ្មែរអីគេខ្លះដែរមីងដូចជាចោលឈូង ទាញព្រាត
បោះអង្គុញអីចឹងហាសមីង?

ខៈ ខ្ញុំអត់ចេះលេងទេតាំងពីតូចចេះលេង។

កៈ តែមីងចូលចិត្តមើលគេអត់មីង?

ខៈ ចូលចិត្តមើលមួយម្លែតៗ ចូលចិត្តនឹងរឿងការងារ
នឹងរឿងការងារលក់ដូរអីចូលចិត្តតិចតួច។

កៈ
ចុះមីងតើមីងមានចងចាំបទចំរៀងណាដែរតាំងពីតូចរហូតមកដល់អាឡូវមីងនៅតែចេះទេមីង?

ខៈ ភ្លេចអស់ហើយ។

កៈ និយាយថាចំរៀងអីហាសមីងចេះច្រៀងទេមីង?

ខៈ អត់ទេ។

កៈ អត់ទេណាមីងតែមីងចូលចិត្តស្តាប់ទេមីង?

ខៈ ចូលចិត្តស្តាប់ ចូលចិត្តស្តាប់ទេស។

កៈ ចូលចិត្តស្តាប់លោកទេសមែន?

ខៈ ខ្ញុំចូលចិត្តស្តាប់លោកទេស ហើយនឹងចូលចិត្តទៅវត្តទៅវ៉ាកាន់សិល្ប៍5។

កៈ មីងនឹងហោស?

ខៈ ខ្ញុំនឹងហើយកាលពីលើកមុននឹងបួសអោយពេលបួសអោយយាយទៅកាន់សិល្ប៍5
ក៏បួសអោយក្មួយវត្តគគូរ ហើយបួសអោយយាយនៅវត្តផ្ទាល់បួសអោយយាយនឹងបាន7ខែ
ហើយបួសអោយក្មួយនឹងបាន4ខែនៅវត្តគគូរនឹងកាលបួសអោយយាយនឹងបាន7ខែនៅវត្ត

ផ្កាល ហើយនឹងបួសអោយក្មួយនៅវត្តគគូរនឹងបាន4ខែ ហើយសព្វថ្ងៃនឹងកាន់សិល្ប៍5ត្រីក៏មិនសំលាប់ អីក៏មិនសំលាប់ដែរនឹងហើយឈប់ហើយ។

កៈ ចុះមីងនៅក្នុងផ្ទះរបស់មីងតើមាននរណាម្នាក់ចេះលេងឧបករណ៍តន្ត្រីខ្មែររឺក៏ឧបករណ៍តន្ត្រីសម័យអីទេមីង?

ខៈ អត់មាននរណាចូលចិត្តមានតែក្មួយអាច្រូចហោស។

ក. ចឹងគាត់ចេះលេង។

ខៈ វាចូលចិត្តលេង លេងរាំអីលេងតែវានឹង។

កៈ គាត់ចេះលេងអីគេដែរមីង?

ខៈ រាំឡេឡេកៗនោះ។

កៈ គាត់ចេះតែរាំទេណមីង?

ខៈ នឹងហើយ។

កៈ ចុះមីងផ្ទះរបស់មីងមានលក្ខណៈម៉េចដែរតាំងពីតូចរហូតមកដល់ពេលនេះហាសណាស់មីង?

ខៈ ផ្ទះហោស?

កៈ ចាផ្ទះរបស់មីងហាស?

ខៈ ក្រកំសត់ដែរពីដើមផ្ទះស្បូវដល់ពេលម៉ែទិញផ្ទះមក9ម៉ែត 9ជ្រុង ហើយផ្ទះបាយហោសប្រហែលជា4ម៉ែតជាងផ្ទះធំដែរផ្ទះបាយហោស។

កៈ ចឹងមីងមានការផ្ទះផ្លាស់ប្តូរដែរណមីងណា ចុះមីងតើមីងបានជួយសាងសងផ្ទះនឹងទេមីង?

ខៈ ជួយតា។

កៈ មីងអ្នកជួយធ្វើដែរមីងចេះធ្វើអត់?

ខ៖ អត់ចេះទេធ្វើផ្ទះ។

ក៖ មីងដឹងគេប្រើឧបករណ៍អីសំរាប់មកធ្វើផ្ទះទេ?

ខ៖ ចេះតែជួយចេះបោះសំអាត។

ក៖ ចឹងមីងគ្រាន់តែបោះច្រាស់តែប៉ុណ្ណឹងទេណា?

ខ៖ នឹងហើយតែបោះសំអាត។

ក៖ ចុះមីងមានជំនាញអីដែរមីងចេះពីក្រុមគ្រួសាររបស់មីងទៀតទេមីង?

ខ៖ នៅនេះហេស?

ក៖ ដូចជាជំនាញអីដែរមីងចេះមកពីជីដូនជីតារឺក៏ម្តាយឪពុករបស់មីងហាសដូចជាវេញវែរ កូរស្កររឺមួយក៏កិច្ចការអីផ្សេងៗទៀតដែរមីងបានចេះពីពួកគាត់ចឹងហាសណាស់?

ខ៖ ចេះពីគាត់ហោសចេះបុកម្រឹក ចេះស្លម្ជូរ

ក៖ ចឹងមីងចេះធ្វើម្ហូបពីពួកគាត់ណាមីង?

ខ៖ ចេះធ្វើម្ហូប ស្ងោរមាន់ ស្ងោរ ស្លការី ។

ក៖ មួយនឹងមីងចេះពីពួកគាត់?

ខ៖ អានឹងចេះពីពួកគាត់។

ក៖
ចុះមីងតើមីងអាចប្រាប់ពីពេលលំបាករបស់មីងបានទេមីងថាតើពេលណាដែរជីវិតរបស់មីង ពិបាកមែនទែនហាសមីង?

ខ៖ ពិបាកពេលដែរមានប្តីនឹងអែងកម្មជាងគេ ហើយកំសត់ជាងគេ
គេរកលែងយើងចោលតាមកូនគេហើយគេព្រមនៅជាមួយកូនគេហាសអោយគេនៅចុះខ្ញុំមិនថាអីទេ
ថាបើលែងក៏លែងចុះតែកុំមកវៃខ្ញុំតែវៃខ្ញុំលើកនេះខ្ញុំប្តឹងហើយថាកាប់ខ្ញុំស្លាប់បងប្អូនគេគេតវ៉ាហើយថាបើមិនសុខចិត្តលែងទៅខ្ញុំថាចឹងកុំអោយខ្ញុំទើសភ្នែកដោយសារគាត់រាល់តែថ្ងៃពេកខ្ញុំកាប់ខ្លួនអែង។

ក៖
ចុះមីងឈ្នះឧបសគ្គនឹងដោយរបៀបណាដែរមីងដូចជាតើមីងធ្វើយ៉ាងម៉េចដើម្បីជំនះនៅឧបសគ្គនឹងការលំបាកនឹងបានហាសណាស់?

ខ៖ នឹងហោសរឿងនឹងហោសចុះបើខ្ញុំមិនមែន។

ក៖
អត់ទេចង់និយាយថាមួយនឹងមីងគិតថាពិបាកនៅក្នុងជីវិតរបស់មីងតើមីងធ្វើយ៉ាងម៉េចដើម្បីជំនះនៅឧបសគ្គទាំងអស់នឹង?

ខ៖ ខ្ញុំធ្វើបុណ្យ។

ក៖ ចាចឹងមីងមានតែខំធ្វើល្អចឹងហាសណាស់។

ខ៖ ខំធ្វើល្អធ្វើបុណ្យ ធ្វើទាន ហើយអោយគេ
លក្ខណះថាធ្វើបុណ្យធ្វើទានហើយអោយថ្នាំទៅគេទៅ និយាយថ្នាំម្តង មហារីស្បូន
ដុះផ្សិតក្នុងស្បូន ថ្នាំសរសៃស្បូនអាចជាទាំងអស់ពេទ្យមើលមិនជាទេ។

ក៖ ចឹងមីងខំល្អជាមួយគេ។

ខ៖ ធ្វើល្អហើយអោយទានគេម្នាក់2-3កញ្ចប់អីចឹងទៅ។

ក៖ ចុះមីងតើពេលណាដែរមីងគិតថាមីងសប្បាយចិត្តហាសមីង
គិតថាពេលណាដែរចឹងហាសមីង?

ខ៖ មានតែបុណ្យទេដែរគិតថាសប្បាយបាន។

ក៖ អូចឹងនៅពេលដែរមីងធ្វើល្អមីងមានអារម្មណ៍ថាសប្បាយចិត្ត។

ខ៖ នឹងហើយបានសប្បាយចិត្ត
ហើយបើធ្វើអាក្រក់មិនដែរទៅទេបើថាមីងមីងនៅក្នុងផ្ទះនេះរឿងថាណាមីងបាច មីងចៃសចុះមីងអាចចៃសបានក្នុងផ្ទះនេះហាសគេថាយើងយកទឹកនោមប្រុសមកអីៗចឹងហាតាមពិតមិនមែនទេយើងយកមកបាចដំណាំយើងអោយល្អទេបាចដំណាំអោយវាល្អទេមិនមែនទៅធ្វើអំពើរទៅលើនរណាគេទេអ្នកនៅក្នុងផ្ទះនេះមិនចេះធ្វើអំពើអាក្រក់ដាក់ទៅលើនរណាគេទេនឹងហើយមិនដែរឃើញថាមានក្បាលនរណាមកបាចបោះអីមិនចេះទេចេះធ្វើតែអំពើល្អមានតែបុណ្យទេដែរធ្វើអោយសប្បាយចិត្តបើធ្វើអាក្រក់គឺមិនសប្បាយចិត្តទេបើធ្វើ

ល្អនរណាគេហូបចំណីចំណុកអូអោយទានទៅគេទៅណា
ដូចជាថ្នាំអីចឹងហាសធ្វើអោយទានគេទៅធ្វើម៉េចបើយើងមិនអោយក្នុងចិត្តយើងនឹងគឺមិនសប្បាយចិត្តទេបើយើងអោយទៅវាសប្បាយចិត្ត។

កៈ
ចុះមីងកាលពីមីងនៅក្មេងហាសមីងមានធ្លាប់គិតថាតើមីងចង់ធ្វើអីពេលដែរមីងធំឡើងទេមីងដូចជាធ្វើគ្រូពេទ្យ
ធ្វើគ្រូបង្រៀនរឺក៏មានគោលបំណងនៅក្នុងជីវិតរបស់មីងថាចង់ធ្វើអីមួយចឹងហាស?

ខៈ
ចិត្តចង់ធ្វើពេទ្យដែរតែធ្វើវាមិនបានម៉ែមិនអោយរៀនហាសឪពុកថាម៉ែវាអើយអោយកូនទៅរៀនទៅម៉ែហេសអញ់មិនអោយកូនរៀនទេអោយកូនវាល្ងង់ទៅអោយវារៀនចេះដូចអញ់ឪពុកចេះអង់គ្លេស ចេះបារាំង ចេះសៀម ចេះថៃ ចេះទាំងអស់
ចិនក៏ចេះដែរដល់ពេលនឹងទៅគាត់ក៏ស្លាប់បាត់ទៅគ្មានកូនណាចេះតពូជទៀតទាំងអស់ទាំងប្រុស
ទាំងស្រីគ្មាននរណាគេចេះទេហ៊ីឪពុករបស់ខ្ញុំគាត់ចេះបកប្រែកាលគាត់នៅរៀនថ្នាក់ទី9-10គាត់ចេះទាំងអស់កាលពីដើមហាស។

កៈ
ចុះមីងបើមីងអាចនិយាយអីមួយទៅកាន់កូនចៅជំនាន់ក្រោយៗរបស់មីងហាសតើមីងនឹងចង់និយាយផ្តាំផ្ញើរអ្វីខ្លះទៅកាន់ពួកគាត់ហាសមីងថាតើចង់អោយគាត់ខិតខំស្អីគេខ្លះនៅក្នុងជីវិតរបស់គាត់ហាស?

ខៈ មានតែអោយគេខិតខំលក់ដូរ
ហើយធ្វើអំពើល្អធ្វើបុណ្យធ្វើទានទៅខំលក់ដូរទៅអាចជួយយើងអើយចំរើនបាន
ហើយអាយុយើងក៏ចំរើនទៅមុខដែរហើយយើងក៏មានការរីកចំរើនដែរអោយតែយើងខំធ្វើអំពើល្អកំតែធ្វើអំពើអាក្រក់ដាក់គេនឹងហើយ។

កៈ ចឹងមានអីទៀតទេមីង?

ខៈ មានតែប៉ុណ្ណឹងអែង។

ក៖

ចឹងមានតែប៉ុណ្ណឹងទេណាមីងចឹងសំរាប់ខ្ញុំមីងខ្ញុំអរគុណច្រើនដែរមីងបានផ្ដល់ការសំភាសន៍រឺក៏បានពិភាក្សាជាមួយខ្ញុំចឹងហាសណាស់មីងហើយដើម្បីអោយខ្ញុំបានដាក់ការសំភាសន៍មួយនេះទៅក្នុងវេបសាយរបស់សាលាចឹងហាសណាស់មីងចាចឹងជាចុងក្រោយអរគុណច្រើនមីង៕៕៕